**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ** (MRD)
**គម្រោងកែលម្អការតភ្ជាប់ផ្លូវ** (RCIP)

# សេចក្តីប្រកាសជ្រើសរើសបុគ្គលិក

## អ្នកបើកបរ ចំនួន ០១រូប (បំពេញបន្ថែម)

គម្រោងកែលម្អការតភ្ជាប់ផ្លូវថ្នល់ជនបទនៅកម្ពុជាមានជាតុផ្សំចំនួនបួនរួមមាន ៖ (១) ការកែលម្អផ្លូវជាតិ និងផ្លូវខេត្ត (២) ការកែលម្អផ្លូវជនបទ (៣) ការអភិវឌ្ឍស្ថាប័ននិងការគ្រប់គ្រងគម្រោងនិង (៤) ការឆ្លើយតបជាបន្ទាន់ ។ ក្រសួងអភិវឌ្ឍន៍ជនបទជាភ្នាក់ងារអភិវឌ្ឍសមាសភាគទី២ ដែលមានការកែលម្អផ្លូវជនបទ រួមមានកិច្ចការកែលម្អភាពធន់ និងអាកាសធាតុ សុវត្ថិភាព និងការថែរក្សាផ្លូវជនបទដែលមាននៅក្នុងខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ។ គម្រោងនេះចាប់អនុវត្តនៅចន្លោះខែកក្កដា ឆ្នាំ២០២០ ដល់ខែកក្កដា ឆ្នាំ២០២៧ ។ ដើម្បីគាំទ្រ និងសម្រួលដល់ដំណើរការអនុវត្តគម្រោងប្រចាំថ្ងៃ និងការចុះបេសកកម្មទៅតាមខេត្តគោលដៅ គម្រោងសូមប្រកាសជ្រើសរើសបេក្ខជនសម្រាប់មុខតំណែងដូចខាងក្រោម ៖

| មុខតំណែង | ចំនួន | បៀវត្ស/ខែ | ទីកន្លែងបំពេញការងារ |
|---|---|---|---|
| អ្នកបើកបរ | ០១រូប | ២៥០ ដុល្លារ | គម្រោង (RCIP) |

**លក្ខខណ្ឌនៃការជ្រើសរើស ៖**

**១. អ្នកបើកបរ**

- មានអាយុ ២៥-៥៥ឆ្នាំ មានអត្តចរិកល្អ ស្លូតត្រង់ អាចធ្វើការងារជាក្រុម
- មានកាយសម្បទាគ្រប់គ្រាន់ មិនធ្លាប់ពាក់ព័ន្ធនឹងអំពើមិនស្របច្បាប់ណាមួយ
- មានចំណេះដឹងផ្នែកបើកបរ (មានប័ណ្ណបើកបរដែលមានសុពលភាព)
- មានបទពិសោធន៍យ៉ាងតិច ០៣ឆ្នាំឡើងទៅ
- ចេះអាន និងសរសេរអក្សរខ្មែរបានច្បាស់លាស់
- សូមមើលតួនាទី និងភារកិច្ចទទួលខុសត្រូវលម្អិត (TOR) និងតម្រូវការគុណសម្បត្តិសម្រាប់មុខតំណែងខាងលើ នៅក្នុងគេហទំព័ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ www.mrd.com ។

**២. អំពីការដាក់ពាក្យ**

បេក្ខជន បេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមផ្ញើលិខិតដាក់ពាក្យសុំ និងប្រវត្តិរូបសង្ខេប (CV) ដោយមានបញ្ជាក់ព័ត៌មានសម្រាប់ទំនាក់ទំនង (រួមមាន ៖ អាស័យដ្ឋាន លេខទូរស័ព្ទ ឬ អ៊ីម៉ែល) មកកាន់ផ្នែករដ្ឋបាលរបស់គម្រោង RCIP – MRD នៅគ្រប់ម៉ោងធ្វើការ ឬតាមរយៈសារអេឡិចត្រូនិច Email engdiman.mrd@gmail.com ។

ថ្ងៃឈប់ទទួលពាក្យ: **ថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ៥:០០ រសៀល** តាមអាសយដ្ឋាននៅក្នុងបរិវេណក្រសួងអភិវឌ្ឍន៍ជនបទ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ជាន់ទី៦ បន្ទប់លេខ ៦១០ ។ មានតែបេក្ខជនដែលមានឈ្មោះក្នុងបញ្ជីសម្រាំងបេក្ខជនអាទិភាព (shortlist) ប៉ុណ្ណោះ ដែលនឹងទទួលបានព័ត៌មានអំពីការប្រឡងជ្រើសរើស ។

**បញ្ជាក់ ៖** មុខតំណែងនេះជាប្រភេទកិច្ចសន្យា ដូច្នេះបេក្ខជនដែលនឹងត្រូវជ្រើសរើសឱ្យបំពេញការងារត្រូវតែមិនមែនជាមន្ត្រីរាជការស៊ីវិល ។ ក្នុងករណីដែលបេក្ខជនជាមន្ត្រីរាជការស៊ីវិល បេក្ខជននោះត្រូវដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្ស ក្នុងរយៈពេលនៃការបំពេញការងារជាមួយគម្រោង ។